**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស**
**លេខ:** ០០២/ សជណ.ពម
/១៨

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

នៅថ្ងៃសុក្រ ២រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ២០១៨ វេលាម៉ោង៨ និង៣០នាទីព្រឹក នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លង៖

**១- សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៣៤ថ្មី មាត្រា៤២ មាត្រា ៤៩ មាត្រា៥៣ និងមាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។**

**២- សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មក្រមព្រហ្មទណ្ឌ**

**៣- សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។**

**៤. សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាបណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ**

**៥- បញ្ហាផ្សេងៗ៖**

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានសម្រេចអនុម័ត៖

**១- សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៣៤ថ្មី មាត្រា៤២ មាត្រា ៤៩ មាត្រា៥៣ និងមាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។**

ក្នុងគោលដៅពង្រឹងបន្ថែមទៀតនូវ ឯករាជ្យ អធិបតេយ្យពេញបរិបូរណ៍ជារដ្ឋស្មើភាព និងស្មើសិទ្ធិជាមួយនឹងរដ្ឋដទៃទៀត និងប្រឆាំងដាច់ខាតការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ទោះដោយផ្ទាល់ ឬដោយប្រយោលក្តីពីសំណាក់បរទេស ទោះបីក្នុងហេតុផលណាក៏ដោយ ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ គណៈរដ្ឋមន្ត្រីបានសម្រេចស្នើធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ មាត្រា ៣៤ថ្មី មាត្រា៤២ មាត្រា ៤៩ មាត្រា ៥៣ និងមាត្រា ១១៨ថ្មី ដោយផ្តោតលើ៖

-សិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះអោយគេបោះឆ្នោត និងលក្ខខណ្ឌនៃសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ដែលត្រូវកំណត់ក្នុងច្បាប់។

-គណបក្សនយោបាយ សមាគម និងប្រជាពលរដ្ឋគ្រប់រូប ត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ និងមានកាតព្វកិច្ចរួមចំណែក កសាងប្រទេសជាតិ និងការពារមាតុភូមិ។

-កំណត់សមាសភាពសមាជិករាជរដ្ឋាភិបាលដែលមានត្រឹមតែ នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី តែប៉ុណ្ណោះ។

## ២. សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មក្រមព្រហ្មទណ្ឌ

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៧ កថាខណ្ឌទី៣ បានចែងថា អង្គព្រះមហាក្សត្រ មិនអាចរំលោភបំពានបានឡើយ។

ដើម្បីធានាលើកស្ទួយនិងការពារព្រះចេស្តា និងព្រះកិត្តិនាមរបស់អង្គព្រះមហាក្សត្រ ដែលជាព្រះប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា និងដោយមានសំណើពីក្រុមប្រឹក្សាធម្មនុញ្ញផងនោះ ការប្រមាថចំពោះអង្គព្រះមហាក្សត្រត្រូវកំណត់ជាទោសព្រហ្មទណ្ឌ។

បទល្មើសប្រមាថចំពោះអង្គព្រះមហាក្សត្រត្រូវរៀបចំជាមាត្រាថ្មីមួយបន្ថែម គឺមាត្រា ៤៣៧ ស្ទួន ដោយបញ្ចូលទៅក្នុងជំពូកទី១ នៃមាតិកាទី១ នៃគន្ថីទី៤ នៃក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារដូចថា «ការប្រមាថចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំ ទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ទៅ១០លានរៀល។ ចំពោះនីតិបុគ្គលក៏អាចត្រូវបានផ្តន្ទាទោសពិន័យជាប្រាក់ពី ១០លានរៀលទៅ៥០លានរៀល ព្រមទាំងទោសបន្ថែមមួយ ឬច្រើនក្នុងករណីដែលតុលាការរកឃើញថាមានពិរុទ្ធភាព ពាក់ព័ន្ធនឹងការប្រមាថចំពោះអង្គព្រះមហាក្សត្រ។

## ៣. សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

យោងតាមស្មារតីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រុមប្រឹក្សាធម្មនុញ្ញ មានសិទ្ធិពិនិត្យ និងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានបង្កើតដោយព្រះរាជក្រមលេខ ជស/រកម/ ០៤៩៨/ ០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ។

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានធ្វើវិសោធនកម្មជាច្រើនលើក ដែលនាំឱ្យសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញមានការប្រែប្រួលខ្លះៗ ទៅតាមការកំណត់របស់ច្បាប់នេះ ដែលទាមទារឱ្យមានការធ្វើវិសោធនកម្មទៅលើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

សេចក្តីព្រៀងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញគឺធ្វើឡើងដើម្បីឆ្លើយតបនឹងបរិការណ៍ខាងលើ សំដៅធានាឱ្យមានភាពរលូន សង្គតិភាព និងឯកភាពនៃច្បាប់ព្រមទាំងធានាឱ្យមានការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព។៧

### ៤. សេចក្ដីព្រាងច្បាប់ស្ដីពីអាជ្ញាបណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ

សេចក្ដីព្រាងច្បាប់នេះ បានរៀបចំឡើងដោយផ្អែកតាមវាក្យខណ្ឌទី៦ នៃសេចក្ដីប្រកាសទីក្រុងដូហា (Doha) ស្ដីពីកិច្ចព្រមព្រៀងទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងសិទ្ធិបញ្ញា និងសុខភាពសាធារណៈ តាមសេចក្ដីសំរេចរបស់អគ្គក្រុមប្រឹក្សានៃអង្គការពាណិជ្ជកម្មពិភពលោក ក៏ដូចជាតម្រូវការចាំបាច់សម្រាប់ប្រទេសកម្ពុជា។

សេចក្ដីព្រាងច្បាប់នេះមានគោលបំណងលើកកម្ពស់សិទ្ធិទទួលបាននូវផលិតផល ឱសថសម្រាប់សុខភាពសាធារណៈ តាមរយៈការផ្ដល់អាជ្ញាបណ្ណបញ្ជាឱ្យផលិត នាំចេញ និងនាំចូលផលិតផលឱសថក្នុងកាលៈទេសៈប្រទេសជាតិមានអាសន្ន ឬកាលៈទេសៈបន្ទាន់ផ្សេងទៀត ឬប្រើប្រាស់ជាសាធារណៈមិនមានលក្ខណៈពាណិជ្ជកម្ម ឬស្ថានភាពសុខភាពសាធារណៈផ្សេងទៀតដែលកំណត់ដោយក្រសួងសុខាភិបាល។

### ៥- បញ្ហាផ្សេងៗ៖

ដើម្បីលើកតំកើងព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ ស្របតាមបាវចនា៖ "ជាតិ សាសនា ព្រះមហាក្សត្រ" សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានសម្រេច៖ នៅគ្រប់ពិធីទាំងអស់ដែលមានព្រះសង្ឃនិមន្តចូលរួម ត្រូវរៀបចំអាសនៈសម្រាប់ព្រះសង្ឃបានគង់នៅខ្ពស់ជាងឧបាសក ឧបាសិកា ឬគ្រហស្ថធម្មតា ហើយក្រសួងធម្មការ និងសាសនាត្រូវធ្វើការណែនាំការងារនេះអោយបានជ្រួតជ្រាប ទូលំទូលាយ និងមានប្រសិទ្ធភាពខ្ពស់។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១១ និង ២០នាទី។

ថ្ងៃសុក្រ ០២ រោច ខែមាឃ ឆ្នាំ រកា នព្វស័ក ព.ស. ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃសុក្រ ទី០២ ខែកុម្ភៈ ឆ្នាំ ២០១៨